ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ : ០០១ ស.ស.ទ .

# សេចក្តីសំរេច
## ស្តីអំពី
## របៀបរបបការងារ និង ការបែងចែកភារកិច្ច
## របស់ថ្នាក់ដឹកនាំ ក្រសួងមហាផ្ទៃ

### ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពី ការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមការងារចាំបាច់របស់ក្រសួងមហាផ្ទៃ

### សម្រេច

**ប្រការ ១** : កំណត់របៀបរបបការងារ និង បែងចែកភារកិច្ចជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ សំដៅធានាការអនុវត្តច្បាប់ និង ដឹកនាំកិច្ចការទូទៅរបស់ក្រសួងមហាផ្ទៃ ។

**ប្រការ ២** : ចំពោះរដ្ឋមន្ត្រី : **ឯកឧត្តម ស ខេង** ទទួលបន្ទុកដឹកនាំការងាររួមរបស់ក្រសួង គ្រប់គ្រងបញ្ជាចាត់ចែងរាល់សកម្មភាពការងារនៃក្រសួងមហាផ្ទៃទាំងមូល និងទទួលផ្ទាល់ការងារបុគ្គលិក ការងារព័ត៌មាន ការងារភស្តុភារ ហិរញ្ញវត្ថុ និង សវនកម្មផ្ទៃក្នុង។

**ប្រការ ៣** : ចំពោះរដ្ឋលេខាធិការ :

១- **ឯកឧត្តម ឯម សំអាន** : ទទួលជារដ្ឋមន្ត្រីស្តីទីពេលរដ្ឋមន្ត្រីអវត្តមាន និងជួយរដ្ឋមន្ត្រីលើការងារទប់ស្កាត់ និងប្រឆាំងភេរវកម្ម ផែនការងារសន្តិសុខ និងផែនការងារសណ្តាប់ធ្នាប់សាធារណៈ ។

២- **ឯកឧត្តម ព្រុំ សុខា** : ទទួលជួយរដ្ឋមន្ត្រី លើការងារអគ្គលេខាធិការដ្ឋាន ប្រចាំការដោះស្រាយការងារប្រចាំថ្ងៃ ដឹកនាំការប្រជុំស្រាវជ្រាវ និងគំរោង CCJAP ។

៣- **ឯកឧត្តម នុត សារអាន** : ទទួលជួយរដ្ឋមន្ត្រី លើការងារពន្ធនាគារ និងក្រុមប្រឹក្សាអ្នកច្បាប់ ការងារអង្គការក្រៅរដ្ឋាភិបាល (NGO) និងគណបក្សនយោបាយ ។

៤- **ឯកឧត្តម ស៊ិន ពិនសេន** : ទទួលជួយរដ្ឋមន្ត្រី លើការងារបណ្តុះបណ្តាលធនធានមនុស្ស (ខាងនគរបាល) និង ផែនការងារនគរបាលយុត្តិធម៌ ។

៥- **ឯកឧត្តម សក់ សេដ្ឋា** : ទទួលជួយរដ្ឋមន្ត្រី លើការងាររដ្ឋបាលមូលដ្ឋាន (លើកលែងកិច្ចការខ្លះ ដែលត្រូវប្រគល់ជូនរដ្ឋលេខាធិការផ្សេងទទួលបន្ទុក) និងទទួលបន្ទុកលេខាធិការដ្ឋាន គ.ជ.អ.ប ។

៦- **ឯកឧត្តម ទី ច័ន្ទ្រផល** : ទទួលជួយរដ្ឋមន្ត្រី លើគំរោងអភិបាលកិច្ចល្អមូលដ្ឋាន គំរោងអភិវឌ្ឍន៍មូលដ្ឋានខេត្តសៀមរាប និងគំរោងអភិវឌ្ឍន៍ផ្សេងទៀតទាក់ទងជាមួយអង្គការអន្តរជាតិ , World Bank & ADB ។

៧- **ឯកឧត្តម ខាន់ សារឿន** : ទទួលជួយរដ្ឋមន្ត្រី លើផែនការងារព្រំដែន ។

៨- **លោកជំទាវ ជូ ប៊ុនអេង** : ទទួលជួយរដ្ឋមន្ត្រី លើការងារអគ្រានុកូលដ្ឋាន ការងារគោលនយោបាយប្រឆាំងការជួញដូរ ការងារកុមារ និងការងារយេនឌ័រ ។

៩- **ឯកឧត្តម ប៉ុល លឹម** : ទទួលជួយរដ្ឋមន្ត្រី លើការងារអធិការកិច្ច ។

**ប្រការ ៤** : ចំពោះអនុរដ្ឋលេខាធិការ :

១-**ឯកឧត្តម នូ តឿង** : រួមជាមួយ **ឯកឧត្តម សក់ សេដ្ឋា** ជួយកិច្ចការរដ្ឋបាលមូលដ្ឋាន ការងារលេខាធិការដ្ឋាន គ.ជ.អ.ប ។

២-**ឯកឧត្តម សៀង ឡាប្រេស្ស** : រួមជាមួយ **ឯកឧត្តម ព្រុំ សុខា** ជួយការងារសហប្រតិបត្តិការអន្តរជាតិ ការងារ Website និងការងារផ្សព្វផ្សាយអប់រំ ។

៣-**ឯកឧត្តម ឈឹម ជួន** : រួមជាមួយ **ឯកឧត្តម ឯម សំអាន** ជួយការងារទប់ស្កាត់ និងប្រឆាំងភេរវកម្ម ការងារសន្តិសុខ និងផែនការងារសណ្តាប់ធ្នាប់សាធារណៈ ។

៤-**ឯកឧត្តម ឈឹម សុខរ៉េត** : រួមជាមួយ **ឯកឧត្តម នុត សារអាន** ជួយការងារអង្គការក្រៅរដ្ឋាភិបាល និងគណបក្សនយោបាយ ។

៥-**ឯកឧត្តម សោម ឆេង** : រួមជាមួយ **លោកជំទាវ ជូ ប៊ុនអេង** ក្នុងចង្កោមការងារដែលលោកជំទាវ **ជូ ប៊ុនអេង** ទទួលបន្ទុក ។

៦-**ឯកឧត្តម ស៊្រុន ទេវ្យវណ្ណៈ** : រួមជាមួយ **ឯកឧត្តម នុត សារអាន** ជួយការងារពន្ធនាគារ និងក្រុមប្រឹក្សាអ្នកច្បាប់ ។

៧-**ឯកឧត្តម ស្លា ប្រយុទ្ធ** : រួមជាមួយ **ឯកឧត្តម ស៊ិន ពិនសេន** ជួយការងារបណ្តុះបណ្តាលធនធានមនុស្ស ផ្នែកនគរបាល និងផែនការងារនគរបាលយុត្តិធម៌ ។

៨-**ឯកឧត្តម សេង ទៀឡាត់** : រួមជាមួយ **ឯកឧត្តម ព្រុំ សុខា** ក្នុងចង្កោមការងារដែល**ឯកឧត្តម ព្រុំ សុខា** ទទួលបន្ទុក ។

៩-**ឯកឧត្តម គឹម សុវណ្ណ** : រួមជាមួយ **ឯកឧត្តម ប៉ុល លឹម** ជួយការងារអធិការកិច្ច ។

**ប្រការ ៥** : ក្រៅពីភារកិច្ចដូចបានចែងខាងលើ រដ្ឋលេខាធិការ និង អនុរដ្ឋលេខាធិការ គ្រប់រូប ត្រូវបំពេញភារកិច្ចផ្សេងទៀត តាមការប្រគល់ភារកិច្ចរបស់រដ្ឋមន្ត្រី តាមការចាំបាច់ ។

**ប្រការ ៦** : រដ្ឋលេខាធិការ **០១ រូប** មានជំនួយការ **០៤ រូប** ដែលត្រូវតែងតាំងដោយប្រកាស ។ អនុរដ្ឋលេខាធិការ **០១ រូប** មានជំនួយការ **០២ រូប** ដែលត្រូវតែងតាំងដោយប្រកាស ។

**ប្រការ ៧** : អគ្គលេខាធិការដ្ឋាន អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និង នគរបាល អគ្គនាយកដ្ឋានពន្ធនាគារ បណ្ឌិតសភានគរបាលកម្ពុជា និង ក្រុមប្រឹក្សាអ្នកច្បាប់ ត្រូវអនុវត្តភារកិច្ចជំនាញតាមបែបបទរដ្ឋបាល ដោយត្រូវឆ្លងតាមរយៈ រដ្ឋលេខាធិការទទួលបន្ទុកពិនិត្យ ជាមុន នូវរាល់ឯកសារមុននឹងដាក់ជូន រដ្ឋមន្ត្រី ពិនិត្យ សំរេច រឺជ្រាបជាសេចក្តីរាយការណ៍ ។

**ប្រការ ៨** : រាល់លិខិតបទដ្ឋានដែលត្រូវដាក់ជូន រដ្ឋមន្ត្រី ពិនិត្យ សំរេច និង ជ្រាបជាសេចក្តីរាយការណ៍ ត្រូវដាក់មកខុទ្ទកាល័យរដ្ឋមន្ត្រី ។

**ប្រការ ៩** : អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយក នៃអគ្គអគ្គនាយកដ្ឋាន ភស្តុភារ និង ហិរញ្ញវត្ថុ អគ្គនាយក នៃអគ្គនាយកដ្ឋាន រដ្ឋបាលមូលដ្ឋាន អគ្គាធិការ នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល អគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធនាគារ ប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ប្រធានបណ្ឌិតសភានគរបាលកម្ពុជា ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង គ្រប់នាយកដ្ឋាន អង្គភាពចំណុះ គ្រប់សាលាខេត្ត ក្រុង គ្រប់ស្នងការដ្ឋាន នគរបាលខេត្ត ក្រុង និងសាម៉ីខ្លួន ដូចមានចែងក្នុងប្រការ ២, ៣. ៤ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ២០០៨

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

ស ខេង

**កន្លែងទទួល :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី

" ដើម្បីជូនជ្រាប "

- ដូចប្រការ ២,៣.៤ និង ៩ " ដើម្បីអនុវត្ត "
- ឯកសារ កាលប្បវត្តិ .